# ឧបសម្ព័ន្ធ ២

## សេចក្តីពិចារណាលើ ឧបសម្ព័ន្ធ ៥(១) និង ៥(២) ដើមបណ្តឹងរដ្ឋប្បវេណី

| លេខយោង អង្គភាពគាំពារជនរងគ្រោះ | ឈ្មោះពេញ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី | សំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ទាក់ទងការចោទប្រកាន់អំពីកំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ | សេចក្តីពិចារណាលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួន |
|---|---|---|---|
| 16-VSS-00048dd | ហារ ជូ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហាក់ដូចជាបានពឹងផ្អែកទៅលើការបកប្រែជាភាសាអង់គ្លេស មិនត្រឹមត្រូវ។ នៅក្នុងឯកសារដើមជាភាសាខ្មែរ អ្នកដាក់ពាក្យសុំបានសរសេរថា “ម្តាយខ្ញុំឈ្មោះ ឆាយ សំ មិនដែលបានហូបឆ្អែតទេ និងបាត់បង់បងប្អូនជាច្រើន។ ធ្វើការងារធ្ងន់ តាមការកំណត់ ដែលគេដាក់ឲ្យ” ដែលបង្ហាញថាគឺ ម្តាយរបស់អ្នកដាក់ពាក្យសុំ មិនមែនអ្នកដាក់ពាក្យសុំទេ ដែល ត្រូវធ្វើការងារធ្ងន់ ដូចរៀបរាប់នោះ។ ហេតុដូច្នេះ អត្តសញ្ញាណរបស់គាត់ ដែលបញ្ជាក់ថាគាត់ កើតនៅខែកក្កដា ឆ្នាំ១៩៧៩ គឺមិនមែនជាអត្តសញ្ញាណមិនត្រឹមត្រូវនោះទេ។ លើសពីនេះទៀត អង្គហេតុ ដែលថាអ្នកដាក់ពាក្យសុំ កើតនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មិនបានរារាំងគាត់ ក្នុងការទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលនេះទេ។ ដូចដែលសហ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី (D5/1891) គួរត្រូវបាន**ទទួលយក**។ |

| | | | |
|---|---|---|---|
| | | ចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី អាចអះអាងអំពីបញ្ហានៃព្យសនកម្មក្របខណ្ឌពេលវេលាខុសគ្នា ហើយថាតើ ការណ៍នេះ បំពេញបានតាមលក្ខខណ្ឌតម្រូវ នៃចំនួនជនរងគ្រោះដែរឬអត់ គឺត្រូវលម្អិតបន្ថែមនៅដំណាក់កាលជំនុំជម្រះ។ សូមមើល ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ) (ឯកសារ D362) កថាខណ្ឌ ៣៣ ជើងទំព័រ ៤៨។ | |
| 15-VSS-00038 | ជឹម នឿន | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្រព្រឹត្តកំហុស។ អង្គហេតុដែលបានរៀបរាប់ ដោយអ្នកដាក់ពាក្យសុំ គឺស្ថិតនៅក្នុងវិសាលភាព ពេលវេលានិងទីកន្លែង នៃសំណុំរឿង។ ឧក្រិដ្ឋកម្មដែលអ្នកដាក់ពាក្យសុំបានរៀបរាប់ គឺកើតឡើង “នៅក្រោយឆ្នាំ១៩៧៦” នៅស្រុកស្ទោង ខេត្តកំពង់ធំ។ ជាពិសេស អ្នកដាក់ពាក្យសុំ បានទទួលរងព្យសនកម្មពីការជម្លៀសដោយបង្ខំ និងការសម្លាប់ឪពុករបស់គាត់ ដែលត្រូវបានគេចោទថាជា “ជនក្បត់”។ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី (D5/1754) គួរត្រូវបាន**ទទួលយក**។ |
| 16-VSS-00042 | ជិន ស្នួង | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្រព្រឹត្តកំហុស។ អ្នកដាក់ពាក្យសុំ បានរៀបរាប់អំពីការចាប់ខ្លួន និងការសម្លាប់ប្តីរបស់គាត់ នៅក្នុងខេត្តកំពង់ធំ “នៅចុងឆ្នាំ១៩៧៦”។ ឧក្រិដ្ឋកម្មនេះស្ថិតក្នុងវិសាលភាពពេលវេលា និងទីកន្លែងនៃសំណុំរឿង។ ហេតុដូច្នេះ អ្នកដាក់ពាក្យសុំ គួរត្រូវបានទទួលស្គាល់។ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី (D5/1885) គួរត្រូវបាន**ទទួលយក**។ |

| | | | |
|---|---|---|---|
| 16-VSS-00044 | ជួន អឿន | អ្នកដាក់ពាក្យសុំ បានរៀបរាប់អំពីឧក្រិដ្ឋកម្ម ទៅលើរូបគាត់និងប្ដីរបស់គាត់ ដែលកើតឡើងនៅក្នុងឆ្នាំ១៩៧៥ នៅក្នុងខេត្តកំពង់ធំ។ អ្នកដាក់ពាក្យសុំក៏បានរៀបរាប់អំពី ការសម្លាប់បងថ្លៃរបស់គាត់ នៅក្នុងឆ្នាំ១៩៧៦ ដោយមិនបានបញ្ជាក់លម្អិតបន្ថែមឡើយ។<br>ដោយពិចារណាទៅលើចំណុចខាងលើ អ្នកដាក់ពាក្យសុំមិនបានកំណត់ថា សកម្មភាពនេះកើតឡើងនៅក្នុង វិសាលភាពពេលវេលានៃសំណុំរឿងទេ។ នេះមិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា ជនរងគ្រោះមិនបានបង្ហាញថា ជាការពិតដែលគាត់បានទទួលរងការឈឺចាប់ ជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 12-VSS-00432 | គ្រី ឡឹង | ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់ អ្នកដាក់ពាក្យសុំបានរៀបរាប់ ពីហេតុការណ៍ដែលបានកើតឡើង នៅក្នុងខេត្តកំពង់ស្ពឺ ដែលស្ថិតនៅក្រៅវិសាលភាពទីកន្លែងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 16-VSS-00014 | លី ស្រន់ | អ្នកដាក់ពាក្យសុំបានផ្ដល់នូវអង្គហេតុ ដែលមិនស៊ីសង្វាក់គ្នា ទាក់ទងការជម្លៀសរូបគាត់ និងក្រុមគ្រួសារគាត់។ នៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះ អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់គាត់ ត្រូវបានជម្លៀសពីភូមិអណ្ដូងពោធិ៍ ទៅភូមិអំពិលក្រញ៉ាញ់ (ក្នុង | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើប |

| | | | |
|---|---|---|---|
| | | ស្រុកកំពង់សៀម ខេត្តកំពង់ចាម) ហើយត្រូវបានខ្មែរក្រហមបង្ខំឱ្យធ្វើការ១០ថ្ងៃ ក្រោយពេលគាត់ឆ្លងទន្លេរួច។ អ្នកដាក់ពាក្យសុំអះអាងថា គាត់ធ្វើការរហូតដល់ឆ្នាំ១៩៧៩។<br><br>ក៏ប៉ុន្តែ ព័ត៌មានបន្ថែមពីអ្នកដាក់ពាក្យសុំ បានរៀបរាប់ផ្សេងទៅវិញ។ ក្នុងនោះអ្នកដាក់ពាក្យសុំបានបញ្ជាក់ថា គាត់និងប្ដីរបស់គាត់ រស់នៅទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៥ ហើយក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀស អ្នកដាក់ពាក្យសុំ ប្ដីនិងកូនអាយុប្រាំពីរខែរបស់គាត់ ពីទីក្រុងភ្នំពេញ ទៅអមលាំង ខេត្តកំពង់ស្ពឺ ដែលនៅទីនោះគាត់ត្រូវបានបញ្ជាឱ្យធ្វើការ។ អ្នកដាក់ពាក្យសុំក៏បានរៀបរាប់អំពីហេតុការណ៍ នៅឃុំត្រពាំងជ្រូវ ខេត្តកំពង់ស្ពឺ។ ដោយសារតែភាពមិនស៊ីសង្វាក់គ្នានៃទីតាំង (កំពង់ស្ពឺ និងកំពង់ចាម) ក្នុងអំឡុងពេលវេលាតែមួយ គឺមិនអាចកំណត់បានថាតើ ឧក្រិដ្ឋកម្មដែលបានរៀបរាប់ ស្ថិតនៅក្នុងវិសាលភាពទីកន្លែង នៃសំណុំរឿងដែរឬអត់។ | អង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 16-VSS-00015 | ម៉ាន ស្លេះ | ទោះបីជាឧក្រិដ្ឋកម្មជាច្រើន ដែលអ្នកដាក់ពាក្យសុំបានរៀបរាប់ កើតឡើងនៅចុងឆ្នាំ១៩៧៥ ហើយស្ថិតក្រៅវិសាលភាពពេលវេលានៃសំណុំរឿងក្ដី តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងដោយមិនបានពិចារណាទៅលើព្រឹត្តិការណ៍ដែលបានបន្ត នៅក្រោយឆ្នាំ១៩៧៥ ដែលអ្នកដាក់ពាក្យសុំបានរៀបរាប់បន្ថែម នៅក្នុងសក្ខីកម្មរបស់គាត់ ក្នុងសវនាការ សំណុំរឿង ០០២ (ឯកសារ D219/792.1.4)។<br><br>ជាពិសេស អ្នកដាក់ពាក្យសុំបានរៀបរាប់ថា គាត់ត្រូវបានជម្លៀសដោយបង្ខំនៅចុងឆ្នាំ១៩៧៥ ពីស្រុកក្រូចឆ្មារ ទៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ជាមួយប្រពន្ធកូនរបស់គាត់។ នៅទីនោះ អ្នកដាក់ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី (D5/1858) គួរត្រូវបាន**ទទួលយក**។ |

| | | | |
|---|---|---|---|
| | | ពាក្យសុំត្រូវទទួលរង ពលកម្មដោយបង្ខំ និងការបង្អត់អាហារ។ គាត់ត្រូវបានអនុញ្ញាតឲ្យទៅជួបប្រពន្ធគាត់ "ម្តងពីរដងក្នុងមួយឆ្នាំ"។ អង្គហេតុទាំងអស់នេះ ស្ថិតក្នុងវិសាលភាពពេលវេលា និងទីកន្លែងនៃសំណុំរឿង។ | |
| 12-VSS-00583 | ម៉ៅ វ៉ា | ចំពោះការបាត់ខ្លួនបងប្រុសរបស់អ្នកដាក់ពាក្យសុំ នៅក្នុងឆ្នាំ១៩៧៥ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពន្យល់រួចហើយ ការណ៍នេះគឺស្ថិតក្រៅវិសាលភាពពេលវេលា នៃសំណុំរឿង។ ចំពោះឧក្រិដ្ឋកម្មដែលបានរៀបរាប់ថា បានប្រព្រឹត្តឡើងនៅក្នុងខេត្តស្វាយរៀង និងខេត្តកណ្តាល ឧក្រិដ្ឋកម្មទាំងអស់នេះ ស្ថិតក្រៅវិសាលភាពទីកន្លែងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 16-VSS-00071 | នូ សារីម | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្រៅវិសាលភាពទីតាំងនៃសំណុំរឿង គឺនៅទីក្រុងភ្នំពេញ ខេត្តកណ្តាល ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។<br>បន្ថែមលើនេះ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពន្យល់ ចំពោះឧក្រិដ្ឋកម្មមួយចំនួនដែលមានបញ្ជាក់ពីកាលបរិច្ឆេទ ពេលវេលាពីឆ្នាំ១៩៧៥ ដល់ពាក់កណ្តាលឆ្នាំ១៩៧៦ ក៏ស្ថិតនៅក្រៅវិសាលភាពពេលវេលានៃសំណុំរឿងដែរ។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 16-VSS-00020 | ផន សុផាត | បើតាមការរៀបរាប់របស់គាត់ អ្នកដាក់ពាក្យសុំនិងក្រុមគ្រួសាររបស់គាត់ បានទទួលរងព្យសនកម្ម ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មជាច្រើន ដែលប្រព្រឹត្តឡើងទៅលើរូបគាត់ និងក្រុមគ្រួសារ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យ |

| | | | |
|---|---|---|---|
| | | របស់គាត់ នៅក្នុងឆ្នាំ១៩៧៦ នៅស្រុកព្រៃឈរនិងស្រុកកំពង់សៀម ក្នុងខេត្តកំពង់ចាម ភូមិភាគកណ្តាល។ ទោះបីជាមានភាពមិនច្បាស់លាស់ថាតើ ឧក្រិដ្ឋកម្មទាំងអស់នេះភាគច្រើន ត្រូវបានប្រព្រឹត្តឡើងនៅចុងឆ្នាំ១៩៧៦ និងពេលបន្ទាប់មកទៀតដែរឬយ៉ាងណា តែជារឿងមិនសមហេតុផលដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ធ្វើការសន្និដ្ឋានថា ពលកម្មដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀត ដែលបានរៀបរាប់ គឺប្រហែលជាស្ថិតក្រៅវិសាលភាពពេលវេលានៃសំណុំរឿង ដោយសារតែលក្ខណៈនៃពលកម្មដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀត ដែលកើតឡើងជាបន្តបន្ទាប់ នៅក្នុងរបបខ្មែរក្រហម ដូចដែលអ្នកដាក់ពាក្យសុំបានរៀបរាប់។ | សុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី (D5/1863) គួរត្រូវបាន**ទទួលយក**។ |
| 12-VSS-00498 | ពិន ហី | អ្នកដាក់ពាក្យសុំបានរៀបរាប់ ពីការបាត់ខ្លួនស្វាមីរបស់គាត់ នៅស្រុកព្រែកប្រសព្វ ខេត្តក្រចេះ នៅ "ក្រោយថ្ងៃ១៧មេសា ១៩៧៥"។ ពេលវេលាដែលអ្នកដាក់ពាក្យសុំបានរៀបរាប់ គឺមិនជាក់លាក់ច្បាស់គ្រប់គ្រាន់ ដើម្បីកំណត់បានថា ពាក្យសុំតាំងខ្លួនគួរត្រូវបានទទួលយកនោះឡើយ។ ហេតុដូច្នេះមិនមែនជាការមិនសមហេតុផលនោះទេ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថាអង្គហេតុ ស្ថិតនៅក្រៅវិសាលភាពពេលវេលា នៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 11-VSS-00346 | រត់ អេង | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ការសម្លាប់សមាជិកក្រុមគ្រួសាររបស់គាត់ នៅអំឡុងឆ្នាំ១៩៧៦ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។ អ្នកដាក់ពាក្យសុំមិនបានផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់ ដើម្បីសម្រេចថាតើ ហេតុការណ៍នេះកើតឡើងនៅក្នុង វិសាលភាពពេលវេលា នៃសំណុំរឿងដែរឬយ៉ាងណា។ បន្ថែមលើនេះព័ត៌មានមានភាពមិនស៊ីសង្វាក់។ ពីដំបូងអ្នកដាក់ពាក្យសុំ ចោទប្រកាន់ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើប |

| | | | |
|---|---|---|---|
| | | ថា ឧក្រិដ្ឋកម្មកើតឡើងនៅអំឡុងឆ្នាំ១៩៧៧ ហើយក្រោយមកបញ្ជាក់ថា ហេតុការណ៍ទាំងនេះ កើតឡើង នៅអំឡុងឆ្នាំ១៩៧៦។ ហេតុដូច្នេះមិនមែនជាការមិនសមហេតុផលនោះទេ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថាព្រឹត្តិការណ៍ទាំងនេះកើតឡើងនៅក្រៅវិសាលភាពពេលវេលា នៃសំណុំរឿង។ | អង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 12-VSS-00440 | សូ យ៉ិន | ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់ អ្នកដាក់ពាក្យសុំបានរៀបរាប់អំពីឧក្រិដ្ឋកម្មដែលបានកើតឡើង នៅក្នុងខេត្តកំពង់ស្ពឺ ដែលស្ថិតនៅក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ បន្ថែមលើនេះ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់ផងដែរ មិនអាចកំណត់បានទេថា ឧក្រិដ្ឋកម្មដែលបានរៀបរាប់ ថាកើតឡើងនៅក្នុងឆ្នាំ១៩៧៦ ស្ថិតនៅក្នុងវិសាលភាពពេលវេលា នៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 11-VSS-00032 | ស៊ឹម រឿន | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ការសម្លាប់ប្តីរបស់គាត់ នៅភ្នំប្រុសភ្នំស្រី ខេត្តកំពង់ចាម និងការរៀបការដោយបង្ខំរបស់គាត់ នៅស្រុកកំពង់សៀម។ នៅក្នុងពាក្យសុំតាំងខ្លួនដំបូងរបស់គាត់ គាត់មិនបានផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់ ដើម្បីសម្រេចថាតើហេតុការណ៍ទាំងអស់នេះ ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងដែរឬអត់ទេ ដោយអ្នកដាក់ពាក្យសុំ គ្រាន់តែបញ្ជាក់ថាការសម្លាប់ និងការរៀបការដោយបង្ខំ កើតឡើងនៅក្នុងឆ្នាំ១៩៧៦។ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី (D5/219) គួរត្រូវបាន**ទទួលយក**។ |

| | | | |
|---|---|---|---|
| | | ប៉ុន្តែនៅក្នុងទម្រង់ព័ត៌មានបន្ថែម អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា ការរៀបការដោយបង្ខំ កើតឡើងនៅចុងឆ្នាំ១៩៧៦ ។ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នេះ ស្ថិតនៅក្នុងវិសាលភាពពេលវេលា និងទីតាំងនៃសំណុំរឿង ហេតុដូច្នេះ ជាការមិនសមហេតុផល ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថាហេតុការណ៍ដែលបានចោទប្រកាន់ ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង។ | |
| 12-VSS-00560 | ស្វាយ ម៉ុន | អ្នកដាក់ពាក្យសុំបានរៀបរាប់ អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងខេត្តកំពង់ស្ពឺ នៅក្នុងឆ្នាំ១៩៧៨។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អះអាងដោយខុសឆ្គងថា ពាក្យសុំតាំងខ្លួនស្ថិតក្រៅវិសាលភាពពេលវេលា នៃសំណុំរឿងក្ដី តែពាក្យសុំតាំងខ្លួននៅតែមិនអាចទទួលយកបាន ដោយសារតែអង្គហេតុដែលបានរៀបរាប់ ស្ថិតនៅក្រៅវិសាលភាពទីតាំងនៃសំណុំរឿង គឺស្ថិតក្រៅភូមិភាគកណ្ដាល។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 11-VSS-00337 | ទូន ប្រុញ | ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបកស្រាយ ពាក្យសុំតាំងខ្លួនស្ថិតក្រៅវិសាលភាពនៃសំណុំរឿង។<br>ចំពោះការសម្លាប់បងប្អូនជីដូនមួយ របស់អ្នកដាក់ពាក្យសុំ ដូចបានរៀបរាប់ថាកើតឡើងនៅឆ្នាំ១៩៧៥ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ហេតុការណ៍នេះស្ថិតក្រៅ វិសាលភាពពេលវេលានៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| | | ចំពោះការសម្លាប់បងប្រុសអ្នកដាក់ពាក្យសុំ ដូចបានរៀបរាប់ថាកើតឡើង នៅចុងឆ្នាំ១៩៧៨ នៅខេត្តបន្ទាយមានជ័យ ហេតុការណ៍នេះស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ | |
| 11-VSS-00178 | យ៉ាន់ សាន | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពីឧក្រិដ្ឋកម្មផ្សេងៗជាច្រើន ដែលបានកើតឡើងនៅខេត្តមណ្ឌលគិរី ដែលស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។<br><br>បន្ថែមលើនេះ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបកស្រាយ ឧក្រិដ្ឋកម្មដែលរៀបរាប់ថា បានធ្វើឡើងចំពោះស្វាមីនិងកូនប្រុស របស់អ្នកដាក់ពាក្យសុំ កើតឡើងនៅក្នុងឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ ដូច្នេះគឺស្ថិតនៅក្រៅវិសាលភាពពេលវេលា នៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 11-VSS-00100 | អ៊ាម ណៃអូន | ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបកស្រាយ ក្របខណ្ឌពេលវេលានៃឧក្រិដ្ឋកម្មដែលបានរៀបរាប់ (គឺការសម្លាប់ប្តីអ្នកដាក់ពាក្យសុំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅខេត្តកំពង់ចាម) មិនត្រូវបានបញ្ជាក់ឡើយ។<br><br>ពេលវេលានៃឧក្រិដ្ឋកម្មមិនមានភាពជាក់លាក់គ្រប់គ្រាន់ ដើម្បីកំណត់ពីវិសាលភាពពេលវេលានៃហេតុការណ៍។ នេះមិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា ជនរងគ្រោះមិនបានបង្ហាញថា ជាការពិតដែលគាត់បានទទួលរងការឈឺចាប់ ជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| 12-VSS-00624 | ដោក សុខគីន | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ឧក្រិដ្ឋកម្មជាច្រើនដែលធ្វើឡើងទៅលើរូបគាត់ និងសមាជិកគ្រួសារគាត់ នៅក្នុងខេត្តកំពង់ស្ពឺ តាកែវ ពោធិ៍សាត់ និងបាត់ដំបង។ ឧក្រិដ្ឋកម្មទាំងនេះ សុទ្ធតែស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។<br><br>ក្រៅពីនេះឧក្រិដ្ឋកម្មខ្លះ ដែលបានរៀបរាប់ថាបានកើតឡើង នៅក្នុងឆ្នាំ១៩៧៥ និងពាក់កណ្តាលឆ្នាំ១៩៧៦ គឺស្ថិតនៅក្រៅវិសាលភាពពេលវេលានៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានតម្កល់។ |
| 16-VSS-00052 | ខៀវ តុល | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ឧក្រិដ្ឋកម្មនៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ប៉ុន្តែគាត់មិនបានបញ្ជាក់លម្អិត អំពីពេលវេលាបន្ថែមទៀតឡើយ។ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចង្អុលបញ្ជាក់រួចហើយ កាលបរិច្ឆេទនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទ មានភាពស្រពិចស្រពិលខ្លាំង មិនអាចកំណត់បានថាតើ ឧក្រិដ្ឋកម្មទាំងនោះ កើតឡើងនៅក្នុងវិសាលភាពពេលវេលា នៃសំណុំរឿងដែរឬទេ។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 11-VSS-00024 | ឃី ណាត | ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបកស្រាយ ហេតុការណ៍ដែលបានរៀបរាប់ រួមទាំងការរៀបការដោយបង្ខំ របស់ប្អូនស្រីអ្នកដាក់ពាក្យសុំ នៅក្នុងឆ្នាំ១៩៧៥ នៅស្រុកកំពង់សៀម គឺស្ថិតនៅក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| 11-VSS-00033 | គីម ស៊ាន | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ឧក្រិដ្ឋកម្មដូចតទៅ៖ ការដាក់ឱ្យទៅជាទាសករ និងការព្យាបាលដោយវេជ្ជសាស្ត្រមិនគ្រប់គ្រាន់ ដែលកើតឡើងនៅក្នុងឆ្នាំ១៩៧៥ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម និងការចាប់ខ្លួនបងប្អូនជីដូនមួយ របស់អ្នកជិតខាងអ្នកដាក់ពាក្យសុំ នៅក្នុងឆ្នាំ១៩៧៧ នៅស្រុកមេមត់ ខេត្តកំពង់ចាម (ភូមិភាគបូព៌ា)។ អង្គហេតុដំបូងស្ថិតក្រៅវិសាលភាពពេលវេលានៃសំណុំរឿង ហើយអង្គហេតុបន្ទាប់ ស្ថិតក្រៅវិសាលភាពទីតាំង ដោយសារតែទីតាំងឧក្រិដ្ឋកម្ម គឺនៅក្រៅភូមិភាគកណ្ដាល។<br><br>ជាការមិនខុសឆ្គងទេដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថាពាក្យសុំតាំងខ្លួន មិនអាចទទួលយកបាន ប៉ុន្តែសំអាងហេតុរបស់គាត់ សម្រាប់ការបដិសេធមិនទទួលយក គឺមិនត្រឹមត្រូវ។ បញ្ហានៃពាក្យសុំតាំងខ្លួនគឺមិនមែន ពេលវេលានិងទីតាំងមិនគ្រប់គ្រាន់ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអះអាងនោះទេ ប៉ុន្តែបញ្ហាគឺថាឧក្រិដ្ឋកម្មដែលបានរៀបរាប់ គឺស្ថិតក្រៅវិសាលភាពពេលវេលា និងទីតាំងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 15-VSS-00159 | គង់ ភារិន | អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា គាត់ទទួលរងការឈឺចាប់ ពីពលកម្មដោយបង្ខំ និងការបង្អត់អាហារ នៅក្នុងឆ្នាំ១៩៧៥ នៅខេត្តព្រៃវែង។ អ្នកដាក់ពាក្យសុំក៏បានរៀបរាប់ផងដែរ អំពីការសម្លាប់ឪពុកនិងពូរបស់គាត់ នៅក្នុងខែឧសភា ឆ្នាំ១៩៧៨ នៅស្រុកអូររាំងឪ ខេត្តកំពង់ចាម (ភូមិភាគបូព៌ា)។ ទីតាំងទាំងពីរគឺស្ថិតក្រៅភូមិភាគកណ្ដាល ហើយស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| | | ចំពោះការសម្លាប់ឪពុកក្មេកអ្នកដាក់ពាក្យសុំ នៅវត្តអូរត្រកួន អ្នកដាក់ពាក្យសុំមិនបានបញ្ជាក់ អំពីពេលវេលានៃឧក្រិដ្ឋកម្មនេះទេ ហើយក៏មិនអាចកំណត់បានទេថា តើស្ថិតនៅក្នុងវិសាលភាពពេលវេលា នៃសំណុំរឿងដែរឬអត់។ នេះមិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា ជនរងគ្រោះមិនបានបង្ហាញថា ជាការពិតដែលគាត់បានទទួលរងការឈឺចាប់ ជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ | |
| 16-VSS-00016 | ម៉ាត់ កើ | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ឧក្រិដ្ឋកម្មជាច្រើនដែលធ្វើឡើងទៅលើរូបគាត់ និងសមាជិកគ្រួសារគាត់ និងការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាម។ អ្នកដាក់ពាក្យសុំមិនបានផ្តល់ពេលវេលាជាក់លាក់ សម្រាប់ឧក្រិដ្ឋកម្ម ប៉ុន្តែតាមបរិបទគឺហាក់ដូចជាថា គាត់ប្រហែលជារៀបរាប់អំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅពាក់កណ្តាលទៅចុងឆ្នាំ១៩៧៥។ ហេតុដូច្នេះ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបកស្រាយ ព័ត៌មានគឺមិនគ្រប់គ្រាន់ដើម្បីសម្រេចថា ពាក្យសុំតាំងខ្លួនស្ថិតក្នុងវិសាលភាពពេលវេលា នៃសំណុំរឿង។<br><br>លើសពីនេះទៀត ទីតាំងនៃឧក្រិដ្ឋកម្មដែលបានរៀបរាប់ គឺស្ថិតក្រៅភូមិភាគកណ្តាល គឺនៅបណ្តាភូមិនានានៃស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម (ភូមិភាគបូព៌ា) ដែលដូច្នេះហើយគឺស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 11-VSS-00058 | មាស ស៊ត | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ការទទួលរងពលកម្មដោយបង្ខំ នៅខេត្តកំពង់ធំ ក្នុងឆ្នាំ១៩៧៥ "រហូតដល់ថ្ងៃរំដោះ" បើទោះបីជាជើងរបស់គាត់ត្រូវពិការ ដោយសារតែធ្វើការធូន់ហួសហេតុ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យ |

| | | | |
|---|---|---|---|
| | | ក្តី។ គាត់ក៏បានរៀបរាប់ផងដែរអំពី ហេតុការណ៍ដទៃទៀតនៅក្នុងឆ្នាំ១៩៧៨។ ចំពោះការបាត់ខ្លួនបងប្រុស របស់អ្នកដាក់ពាក្យសុំ ពេលវេលានិងទីតាំងបាត់ខ្លួន គឺមិនបានបញ្ជាក់ឡើយ។<br>ទោះបីជាអ្នកដាក់ពាក្យសុំ មិនអាចផ្តល់ព័ត៌មានលម្អិតបន្ថែមក្តី ក៏មានព័ត៌មានគ្រប់គ្រាន់ដើម្បីស្វែងរកថា យ៉ាងហោចណាស់មានឧក្រិដ្ឋកម្មមួយចំនួន ស្ថិតក្នុងវិសាលភាពពេលវេលា និងទីតាំងនៃសំណុំរឿង។ ពាក្យសុំតាំងខ្លួនគួរត្រូវបានទទួលយក។ | សុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី (D5/19) គួរត្រូវបាន**ទទួលយក**។ |
| 12-VSS-00484 | អ៊ូ សន | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ឧក្រិដ្ឋកម្មនានាដែលធ្វើឡើងទៅលើរូបគាត់ និងសមាជិកគ្រួសារគាត់ នៅតាមទីតាំងជាច្រើនក្នុងខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។ ទីតាំងមួយចំនួនមិនច្បាស់លាស់ ប៉ុន្តែហាក់ដូចជាស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង។ ហេតុដូច្នេះមិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា ជនរងគ្រោះមិនបានបង្ហាញថា ជាការពិតដែលគាត់បានទទួលរងការឈឺចាប់ ជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ជាពិសេសអង្គហេតុដែលបានរៀបរាប់ គឺស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 11-VSS-00068 | ពួក ជាម | អ្នកដាក់ពាក្យសុំបានរៀបរាប់ ពីការសម្លាប់បងប្អូនបង្កើតរបស់គាត់ នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នៅក្នុងឆ្នាំ១៩៧៦ រួមនឹងការធ្វើពលកម្មដោយបង្ខំ និងការបង្អត់អាហារ។ ពេលវេលាគឺមិនត្រូវបានបញ្ជាក់ឱ្យជាក់ច្បាស់ឡើយ ដូច្នេះគឺមិនអាចសន្និដ្ឋានបានទេថា ហេតុការណ៍ទាំងអស់នេះកើតឡើងនៅក្នុងវិសាលភាពពេលវេលា នៃសំណុំរឿង។ ហេតុដូច្នេះ មិនមែនជារឿងមិនសម | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើប |

| | | | |
|---|---|---|---|
| | | ហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា ហេតុការណ៍គឺស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង។ | អង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 12-VSS-00445 | សៅ ណាម | ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបកស្រាយ អ្នកដាក់ពាក្យសុំបានរៀបរាប់ អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងខេត្តកំពង់ស្ពឺ ដែលស្ថិតក្រៅវិសាលភាពទីតាំង នៃសំណុំរឿង។<br><br>ក្រៅពីនេះដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់ គឺមិនអាចកំណត់បានទេថា ឧក្រិដ្ឋកម្មដែលបានរៀបរាប់ ថាបានកើតឡើង "មួយថ្ងៃ" នៅក្នុងឆ្នាំ១៩៧៦ ស្ថិតក្នុងវិសាលភាពពេលវេលានៃសំណុំរឿងនោះ។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 15-VSS-00018 | សូត្រ ហាន | អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា បងប្រុសរបស់គាត់ត្រូវបានជម្លៀស ទៅខេត្តបាត់ដំបង ហើយត្រូវបានសម្លាប់នៅទីនោះ (មិនមានកាលបរិច្ឆេទជាក់លាក់)។ ពេលវេលានៃការសម្លាប់គឺមិនជាក់លាក់ ហើយសំខាន់បំផុតនោះ ទីតាំងឧក្រិដ្ឋកម្មស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 16-VSS-00028 | ស៊ាង អឿន | ការរៀបរាប់របស់អ្នកដាក់ពាក្យសុំ គឺមិនច្បាស់លាស់អំពីពេលវេលា និង/ទីកន្លែង ហើយហាក់ដូចជាមិនស៊ីសង្វាក់គ្នា។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេច |

| | | | |
|---|---|---|---|
| | | នៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះរបស់គាត់ ជាដំបូងអ្នកដាក់ពាក្យសុំបានរៀបរាប់ អំពីការស្លាប់របស់សាច់ញាតិគាត់ ដែលត្រូវបានគេបញ្ជា ឱ្យទៅសែងគ្រាប់បែកឱ្យពួកខ្មែរក្រហម។ បើតាមអ្នកដាក់ពាក្យសុំ សាច់ញាតិទាំងនេះគឺ បងប្រុសឈ្មោះ សឿន, រឿន និង សំអាត ហើយនិងប្ដីរបស់អ្នកដាក់ពាក្យសុំ នៅក្នុងភូមិតាអ៊ុង ឬភូមិចម្រើនផល ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅក្នុងឆ្នាំ១៩៧៥ អ្នកដាក់ពាក្យសុំអះអាងថា គាត់ត្រូវទទួលរងពលកម្មដោយបង្ខំ នៅក្នុងភូមិអណ្ដូងពោធិ៍ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។<br><br>នៅក្នុងទម្រង់ព័ត៌មានបន្ថែមរបស់គាត់ អ្នកដាក់ពាក្យសុំបានរៀបរាប់អំពីបងប្រុសឈ្មោះ រឿន ដែលត្រូវបានកងទ័ពខ្មែរក្រហមសម្លាប់។ ពេលវេលានិងទីតាំងគឺមិនបានបញ្ជាក់។<br><br>អ្នកដាក់ពាក្យសុំក៏បានរៀបរាប់អំពី ការឃុំឃាំងបងប្រុសឈ្មោះ សឿន នៅវត្តអង្គញ្ញជី ហើយប្រហែលជាត្រូវសម្លាប់នៅទួលបេង។ ពេលវេលាគឺមិនបានបញ្ជាក់។<br><br>បន្ទាប់មកអ្នកដាក់ពាក្យសុំ បានរៀបរាប់អំពីការស្លាប់របស់ប្ដីគាត់ នៅមន្ទីរពេទ្យស្ពឺ ដោយសារតែជំងឺ និងធ្វើការធ្ងន់។ ពេលវេលាមិនបានបញ្ជាក់។<br><br>ជាចុងក្រោយអ្នកដាក់ពាក្យសុំ បានរៀបរាប់អំពីការស្លាប់របស់ ប្អូនប្រុសឈ្មោះ សំអាត ពេលដែលគាត់នៅក្នុងកងទ័ពខ្មែរក្រហម នៅស្រុកចំការលើ ខេត្តកំពង់ចាម។ ពេលវេលាមិនបានបញ្ជាក់។ | របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានតម្កល់។ |

| | | | |
|---|---|---|---|
| | | ព័ត៌មានដែលបានផ្តល់ទាំងពីរ គឺខុសគ្នាលើខ្លឹមសារ ដូចជាមនុស្សដដែលម្តងនិយាយថាស្លាប់ ដោយសារពលកម្មដោយបង្ខំនៅទីតាំងជាក់លាក់មួយ ហើយម្តងទៀតនិយាយថាត្រូវបានសម្លាប់ នៅទីតាំងមួយផ្សេងទៀត។ បន្ថែមលើនេះនិងសំខាន់បំផុតនោះ ដោយសារតែពេលវេលាមិនច្បាស់លាស់ អ្នកដាក់ពាក្យសុំមិនបានកំណត់ថា អង្គហេតុស្ថិតក្នុងវិសាលភាពពេលវេលា នៃសំណុំរឿងឡើយ។ នេះមិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា ជនរងគ្រោះមិនបានបង្ហាញថា ជាការពិតដែលគាត់បានទទួលរងការឈឺចាប់ ជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទ<br>ប្រកាន់។ | |
| 12-VSS-00577 | តែម វត | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ការសម្លាប់បងប្រុសរបស់គាត់នៅភ្នំប្រុសភ្នំស្រី ក្នុងខេត្តកំពង់ចាម នៅពេលវេលាមួយមិនបានបញ្ជាក់ និងការសម្លាប់បងប្រុសទីពីរម្នាក់ទៀត នៅពេលវេលានិងទីកន្លែងដែលគាត់មិនដឹង។ នេះមិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា កាលបរិច្ឆេទនៃឧក្រិដ្ឋកម្មដែលបានចោទ មានមិនភាពជាក់លាក់គ្រប់គ្រាន់ ដើម្បីកំណត់ថាហេតុការណ៍នេះកើតឡើង នៅក្នុងវិសាលភាពពេលវេលា និង/ឬទីតាំងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| 12-VSS-00486 | ទឹម យិន | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ការស្លាប់របស់កូនទាំងបួននាក់របស់គាត់ នៅចុងឆ្នាំ១៩៧៦ ដើមឆ្នាំ១៩៧៧ ពាក់កណ្តាលឆ្នាំ១៩៧៧ និងក្នុងរដូវធ្វើស្រែឆ្នាំ១៩៧៧ ដោយសារការអត់ឃ្លាន នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។ ទីកន្លែងគឺស្ថិតនៅក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។<br><br>សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឡើយដែលសម្រេចថា ពាក្យសុំតាំងខ្លួនមិនអាចទទួលយកបាន ប៉ុន្តែសំអាងហេតុរបស់គាត់ ក្នុងការបដិសេធមិនទទួលយក គឺមិនត្រឹមត្រូវ។ បញ្ហានៃពាក្យសុំនេះ គឺមិនមែនពេលវេលាមិនច្បាស់លាស់ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិអះអាងឡើយ បញ្ហាគឺថាឧក្រិដ្ឋកម្មដែលបានរៀបរាប់ គឺស្ថិតនៅក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 11-VSS-00065 | ប្រាច សង | មានភាពមិនស៊ីសង្វាក់គ្នា ក្នុងព័ត៌មានដែលអ្នកដាក់ពាក្យសុំបានផ្តល់ ទាក់ទងការស្លាប់របស់ឪពុក និងប្អូនប្រុសរបស់គាត់។ ដំបូងអ្នកដាក់ពាក្យសុំបានបញ្ជាក់ថា គាត់បានឃើញផ្ទាល់ ប្អូនប្រុសរបស់គាត់ត្រូវគេសម្លាប់ នៅក្នុងឆ្នាំ១៩៧៧ នៅភូមិល្វៀង ឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ ហើយថាឪពុករបស់គាត់ត្រូវបានសម្លាប់ នៅក្នុងឆ្នាំ១៩៧៧ នៅភូមិព្រៃរុន ខេត្តតាកែវ។<br><br>ប៉ុន្តែនៅក្នុងទម្រង់ព័ត៌មានបន្ថែមរបស់គាត់ អ្នកដាក់ពាក្យសុំបានបញ្ជាក់ថាប្អូនប្រុសគាត់ ត្រូវបានគេសម្លាប់នៅភូមិពោង ខេត្តតាកែវ ហើយឪពុករបស់គាត់ស្លាប់ដោយសារជំងឺ និងអត់អាហារ។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| | | ដោយមិនគិតពីភាពមិនស៊ីសង្វាក់គ្នា ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់ នោះ ពាក្យសុំតាំងខ្លួនមិនអាចទទួលយកបាន ដោយសារទីតាំងឧក្រិដ្ឋកម្ម ស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ | |
| 11-VSS-00129 | គីម សេង | ឧក្រិដ្ឋកម្មដែលអ្នកដាក់ពាក្យសុំបានរៀបរាប់ ដែលរួមមានការរៀបការដោយបង្ខំ ចំពោះប្អូនស្រីអ្នកដាក់ពាក្យសុំ ការសម្លាប់បងប្អូនស្រីរបស់គាត់ម្នាក់ទៀត ការដាក់ឱ្យទៅជាទាសករ ការអត់អាហារ និងការស្លាប់របស់កូនប្រុសអ្នកដាក់ពាក្យសុំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅតាមទីកន្លែងផ្សេងៗគ្នាក្នុងខេត្តកំពង់ស្ពឺ គឺស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។<br><br>លើសពីនេះទៀត ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់ ការអះអាងរបស់អ្នកដាក់ពាក្យសុំដែលថា នៅចុងឆ្នាំ១៩៧៥ គាត់ត្រូវបានជម្លៀសពីខេត្តកំពង់ស្ពឺ ទៅខេត្តពោធិ៍សាត់ ហើយបន្ទាប់មកទៅខេត្តបាត់ដំបង គឺហាក់ដូចជាមិនស្របគ្នាជាមួយ ការអះអាងរបស់គាត់ដែលថា គាត់ត្រូវទទួលរងពលកម្មដោយបង្ខំ នៅក្នុងខេត្តកំពង់ស្ពឺ ក្នុងឆ្នាំ១៩៧៥-១៩៧៦។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 15-VSS-00066 | គង់ គឹមស៊ាន | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ឧក្រិដ្ឋកម្មជាច្រើនដែលបានប្រព្រឹត្តឡើង នៅក្នុងស្រុកក្រចេះ ខេត្តក្រចេះ ដែលទីតាំងទាំងនេះស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើប |

| | | | |
|---|---|---|---|
| | | | អង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 12-VSS-00415 | ខៀវ ហ៊ីម | អ្នកដាក់ពាក្យសុំបានរៀបរាប់អំពី ឧក្រិដ្ឋកម្មជាច្រើនដែលបានប្រព្រឹត្តឡើង នៅក្នុងខេត្តកំពង់ស្ពឺ ដែលស្ថិតក្រៅវិសាលភាពទីតាំងនៃ<br>សំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 13-VSS-00176 | ឈឿម ឈួន | អ្នកវិនិច្ឆ័យឥតលម្អៀងទៅលើអង្គហេតុ អាចធ្វើការសន្និដ្ឋានថា ភាពមិនស៊ីសង្វាក់គ្នា នៃអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ គឺមិនបានបង្ហាញថា ជាការពិតដែលថាអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ ត្រូវបានបង្ហាញ (ទម្រង់ព័ត៌មានជនរងគ្រោះ បញ្ជាក់កាលបរិច្ឆេទកំណើតនៅឆ្នាំ ១៩៧៧ ចំណែកអ្នកដាក់ពាក្យសុំ បានរៀបរាប់ខ្លួនគាត់ថា គាត់អាយុ១៥ឆ្នាំ នៅក្នុងឆ្នាំ១៩៧៥ ដូច្នេះកាលបរិច្ឆេទកំណត់គឺឆ្នាំ១៩៦០ នៅក្នុងទម្រង់ព័ត៌មានបន្ថែម)។<br>ទោះបីជាវិធីសាស្ត្របែបបទបែន អាចមានភាពសមស្រប ក្នុងការវាយតម្លៃលើអត្តសញ្ញាណ តាមវិធាន២៣ស្ទួនក្តី តែអត្តសញ្ញាណចាំបាច់ត្រូវតែបង្ហាញ។ ដូចដែលសហមេធាវីបានទទួលស្គាល់ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| | | នៅក្នុងសារណាឧបសម្ព័ន្ធ ជ(២) គឺមិនមានឯកសារភ្ជាប់ ដើម្បីឱ្យតុលាការអាចផ្ទៀងផ្ទាត់អត្តសញ្ញាណឡើយ។<br>ហេតុដូច្នេះដីកាសម្រេចដែលរងការជំទាស់ មិនមានកំហុសឡើយ ក្នុងការសម្រេចថាអ្នកដាក់ពាក្យសុំ មិនបានកំណត់អត្តសញ្ញាណខ្លួន ឱ្យបានគ្រប់គ្រាន់នោះ។ | |
| 13-VSS-00307 | ឃៀម សោន | ដូចដែលសហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី បានទទួលស្គាល់នៅក្នុងឧបសម្ព័ន្ធ ជ(២) អ្នកដាក់ពាក្យសុំបានចោទប្រកាន់ផងដែរអំពីការរៀបការដោយបង្ខំនៅខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ) ដែលស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។<br>បន្ថែមលើនេះទឡ្ហីករណ៍របស់ សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលថាអ្នកដាក់ពាក្យសុំ គួរត្រូវបានទទួលយក "នៅក្នុងក្របខណ្ឌសហឧក្រិដ្ឋកម្មរួម" គឺត្រូវតែបដិសេធចោល។ ដូចនៅក្នុងមូលដ្ឋាន ១(ក) ខាងលើ អ្នកដាក់ពាក្យសុំចាំបាច់ត្រូវបង្ហាញ ទំនាក់ទំនងរវាងព្យសនកម្មដែលបានចោទប្រកាន់ ជាមួយឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទៅលើ អោ អាន នៅក្នុងភូមិភាគកណ្តាល។ ព្យសនកម្មរបស់អ្នកដាក់ពាក្យសុំ អាចជាផលវិបាកនៃសហឧក្រិដ្ឋកម្មរួមកម្រិតជាតិ (ដូចជានៅភូមិភាគពាយ័ព្យ) ប៉ុន្តែមិនអាចបំពេញបានសម្រាប់ទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿងនេះ ដូចដែលបានតម្រូវតាមវិធាន ២៣ ស្ទួន (១)(ខ) នៃវិធានផ្ទៃក្នុងឡើយ។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| 13-VSS-00631 | ម៉ៅ សើឡេស | នេះមិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា ពាក្យសុំតាំងខ្លួនមិនអាចទទួលយកបាន ប៉ុន្តែសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបដិសេធមិនទទួលយក គឺមិនត្រឹមត្រូវ។<br><br>ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់ត្រឹមត្រូវថា អង្គហេតុស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿងក្តី តែគាត់មានកំហុសឆ្គងក្នុងការបង្ហាញថា អ្នកដាក់ពាក្យសុំស្ថិតក្រៅវិសាលភាពពេលវេលានៃសំណុំរឿង (ដោយសារអ្នកដាក់ពាក្យសុំ បានរៀបរាប់អំពីហេតុការណ៍ដែលកើតមាន ចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨)។<br><br>មិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា អ្នកដាក់ពាក្យសុំមិនអាចទទួលស្គាល់ ដោយសារតែព្យសនកម្មរបស់អ្នកដាក់ពាក្យសុំ ទាក់ទងជាមួយឧក្រិដ្ឋកម្ម ដែលស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង (នៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម) ដែលមិនស្ថិតនៅក្នុងភូមិភាគកណ្តាល។ ទីតាំងភូមិសាស្ត្រនេះ ត្រូវបានទទួលស្គាល់បន្ថែមដោយសារណា របស់សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលថាអ្នកដាក់ពាក្យសុំ ទទួលរងព្យសនកម្មនៅក្នុងភូមិភាគនិរតី។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 11-VSS-00191 | សាន សុភុម | ដូចដែលសហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី បានទទួលស្គាល់នៅក្នុងសារណាឧបសម្ព័ន្ធ ជ(២) អ្នកដាក់ពាក្យសុំ "រស់នៅ" ក្នុងភូមិភាគនិរតី។ ដោយសារហេតុការណ៍ដែលបានចោទ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើប |

| | | | |
|---|---|---|---|
| | | ប្រកាន់ បានកើតឡើងនៅក្នុងខេត្តបាត់ដំបង និងព្រៃវែង (ភូមិភាគពាយ័ព្យ និងបូព៌ា) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឆ្គងឡើយ ក្នុងការសម្រេចមិនទទួលយក។ | អង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 12-VSS-00843 | តែម ជ្រន | មិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចថា ពាក្យសុំតាំងខ្លួនមិនអាចទទួលយកបាន ប៉ុន្តែសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបដិសេធមិនទទួលយក គឺមិនត្រឹមត្រូវ។<br><br>ដូចដែលសហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានទទួលស្គាល់នៅក្នុងឧបសម្ព័ន្ធ ជ(២) អ្នកដាក់ពាក្យសុំ "រស់នៅក្នុងភូមិភាគនិរតី" ហើយ "មិនដែលរស់នៅក្នុងភូមិភាគកណ្ដាល" ឡើយ។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្ហាញថា ពាក្យសុំតាំងខ្លួន ស្ថិតក្រៅវិសាលភាពពេលវេលាក្ដី តែសំអាងហេតុរបស់គាត់ បានរៀបរាប់អំពីព្រឹត្តិការណ៍ នៅអំឡុងឆ្នាំ១៩៧៨-១៩៧៩ ដែលកើតឡើងនៅក្នុងខេត្តកំពត ឬខេត្តតាកែវ ដែលស្ថិតក្រៅភូមិភាគកណ្ដាល។<br><br>នេះមិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចថា មិនអាចទទួលយកអ្នកដាក់ពាក្យសុំ ដោយសារតែហេតុការណ៍ស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 13-VSS-00429 | ស្ដើង មាច | ដោយសារតែមិនមានព័ត៌មានលម្អិតគ្រប់គ្រាន់ សម្រាប់ការចោទប្រកាន់មួយចំនួន ហើយហេតុការណ៍ដទៃទៀត ដែលបានរៀបរាប់លម្អិតគ្រប់គ្រាន់ ស្ថិតក្រៅវិសាលភាពទីតាំង ដូច្នេះសហ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេច |

| | | | |
|---|---|---|---|
| | | ចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឆ្គងឡើយ។ ជារឿងសមហេតុផលដែលសន្និដ្ឋានថា ជាការមិនពិតដែល អ្នកដាក់ពាក្យសុំ បានទទួលរងព្យសនកម្ម ដែលជាផលវិបាកនៃបទចោទប្រកាន់។<br><br>ទឡ្ហីករណ៍របស់សហមេធាវីដែលថា អ្នកដាក់ពាក្យសុំអាចទទួលស្គាល់បាន ដោយសារតែគាត់គឺជាជនរងគ្រោះដោយផ្ទាល់ នៃការដាក់ឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត "នៅក្នុងក្របខណ្ឌសហឧក្រិដ្ឋកម្មរួម" គឺត្រូវតែបដិសេធចោល។ ទោះបីជាអ្នកដាក់ពាក្យសុំ អាចទទួលរងព្យសនកម្ម ដោយសារតែសហឧក្រិដ្ឋកម្មថ្នាក់ជាតិ (ដូចជានៅភូមិភាគពាយ័ព្យ) ប៉ុន្តែពាក្យសុំតាំងខ្លួនមិនអាចបង្ហាញ ទំនាក់ទំនងរវាងព្យសនកម្ម របស់អ្នកដាក់ពាក្យសុំ ជាមួយឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ នៅក្នុងភូមិភាគកណ្តាល។ សូមមើលមូលដ្ឋាន១(ក) ខាងលើ ដែលបង្ហាញអំពីលក្ខខណ្ឌតម្រូវទំនាក់ទំនង រវាងព្យសនកម្មដែលបានទទួលរង ជាមួយឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ តាមវិធាន ២៣ ស្ទួន (១)(ខ) នៃវិធានផ្ទៃក្នុង។ | របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 13-VSS-00026 | វិញ សាម៉ិញ | មិនមែនជារឿងមិនសមហេតុផលឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចថា ពាក្យសុំតាំងខ្លួនមិនអាចទទួលយកបាន ដោយសារតែឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ស្ថិតក្រៅវិសាលភាពពេលវេលា និងទីតាំងនៃសំណុំរឿង។<br><br>ទឡ្ហីករណ៍របស់សហមេធាវីដែលថា អ្នកដាក់ពាក្យសុំអាចទទួលស្គាល់បាន នៅក្នុងក្របខណ្ឌសហឧក្រិដ្ឋកម្ម គឺចាំបាច់ត្រូវបដិសេធ ដោយសរតែហេតុការណ៍ដែលបានចោទប្រកាន់ (សូម្បី | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| | | ត្រឹមទាក់ទងជាមួយ សហឧក្រិដ្ឋកម្មថ្នាក់ជាតិ) ស្ថិតក្រៅភូមិភាគកណ្ដាល (រួមផងដែរទាំងបន្ទាយមានជ័យ បាត់ដំបង និងភូមិភាគពាយ័ព្យ)។ សូមមើលមូលដ្ឋាន១(ក) ខាងលើ ដែលពិភាក្សាអំពី លក្ខខណ្ឌតម្រូវទំនាក់ទំនង រវាងព្យសនកម្មនិងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ តាមវិធាន ២៣ ស្ទួន (១)(ខ) នៃវិធានផ្ទៃក្នុង។ | |
| 13-VSS-00073 | ជិន សារ៉ៃ | អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា គាត់ធ្វើពលកម្មធ្ងន់ធ្ងរនៅក្នុងឆ្នាំ១៩៧៥ ប៉ុន្តែដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់ ឯកសារអត្តសញ្ញាណរបស់គាត់ ដែលបានផ្ដល់មកជាមួយពាក្យសុំតាំងខ្លួន (ហើយបានបញ្ជាក់ឡើងវិញផងដែរ នៅក្នុងផ្នែកអត្តសញ្ញាណ នៃទម្រង់ព័ត៌មានជនរងគ្រោះរបស់គាត់) បានបញ្ជាក់ថា គាត់កើតនៅក្នុងឆ្នាំ១៩៧៤។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឡើយក្នុងការសន្និដ្ឋានថា អ្នកដាក់ពាក្យសុំគឺជាទារិកា នៅក្នុងឆ្នាំ១៩៧៥ ហេតុដូច្នេះជាការមិនពិតឡើយដែលថា គាត់ទទួលរងព្យសនកម្ម ដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ណាមួយ។<br><br>សំខាន់ជាងនេះ បើទោះបីជាឆ្នាំកំណើតរបស់អ្នកដាក់ពាក្យសុំ នៅក្នុងអត្តសញ្ញាណប័ណ្ណរបស់គាត់ គឺមានកំហុសឆ្គងដោយសារអាជ្ញាធរ ដូចដែលបានលើកឡើងនាពេលនេះក្ដី តែពាក្យសុំតាំងខ្លួនស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ បើយោងតាមអ្នកដាក់ពាក្យសុំ ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនៅទីតាំងផ្សេងៗ ក្នុងខេត្តបន្ទាយមានជ័យ។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្ដីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| 11-VSS-00300 | កែវ កន | នៅក្នុងសារណា ឧបសម្ព័ន្ធ ជ(២) សហមេធាវីគ្រាន់តែទទួលស្គាល់ ពីភាពមិនស៊ីសង្វាក់គ្នានៃកាលបរិច្ឆេទកំណើត របស់អ្នកដាក់ពាក្យសុំ (គឺឆ្នាំ១៩៦៥ នៅក្នុងផ្នែកអត្តសញ្ញាណ និងឆ្នាំ១៩៨២ នៅក្នុងអត្តសញ្ញាណប័ណ្ណ)។<br><br>ដោយសារតែភាពមិនស៊ីសង្វាក់គ្នា នៃកាលបរិច្ឆេទកំណត់ ជាការសមហេតុផលដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថាភាពមិនច្បាស់លាស់ អំពីអត្តសញ្ញាណនេះ "មិនអាចសម្របសម្រួលបាន" ហើយភាពមិនស៊ីសង្វាក់គ្នានេះ ធ្វើឱ្យពាក្យសុំតាំងខ្លួន មិនអាចបំពេញបានតាមលក្ខខណ្ឌតម្រូវអត្តសញ្ញាណ តាមវិធាន ២៣ ស្ទួន (១)(ក) នៃវិធានផ្ទៃក្នុង។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |
| 13-VSS-00164 | ផុន ផ | ទោះបីជាសហមេធាវី បានចង្អុលបង្ហាញថា ដីកាសម្រេចដែលរងការជំទាស់ បញ្ជាក់មិនត្រឹមត្រូវថា អ្នកដាក់ពាក្យសុំបានរំឭកថាគាត់ ជាជនរងគ្រោះដោយផ្ទាល់ នៃការរៀបការដោយបង្ខំក្តី តែការណ៍នេះមិនប៉ះពាល់ដល់ការសម្រេចចុងក្រោយ លើភាពមិនអាចទទួលយកបាន ដែលផ្អែកលើវិសាលភាពទីតាំងនោះទេ។<br><br>ដីកាសម្រេចដែលរងការជំទាស់ មិនមានកំហុសឡើយក្នុងការសន្និដ្ឋានថា អង្គហេតុដែលអ្នកដាក់ពាក្យសុំបានរៀបរាប់  ស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង (ដោយសារតែហេតុការណ៍ដែលបានចោទប្រកាន់ជាច្រើន ដែលអ្នកដាក់ពាក្យសុំបានទទួលរង ដោយផ្ទាល់និងដោយប្រយោល ដូចជា ការផ្លាស់ទីលំនៅដោយបង្ខំ ការដាក់ឱ្យទៅជាទាសករ អំពើមនុស្សឃាត នៅក្នុងខេត្តបន្ទាយមានជ័យ) គឺមិនស្ថិតក្នុងភូមិភាគកណ្តាលឡើយ។ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| 11-VSS-00297 | យ៉ែម ខុន្ធី | ដីកាសម្រេចដែលរងការជំទាស់ មិនមានកំហុសឡើងក្នុងការសន្និដ្ឋានថា ភាពមិនស៊ីសង្វាក់គ្នា រវាង ទម្រង់ព័ត៌មានជនរងគ្រោះ, ទម្រង់ព័ត៌មានបន្ថែម និងសក្ខីកម្មរបស់អ្នកដាក់ពាក្យសុំ គឺមិនអាចបង្ហាញថាជាការពិតដែល អ្នកដាក់ពាក្យសុំបានទទួលរងព្យសនកម្ម ដោយសារតែឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ណាមួយ។ ភាពមិនស៊ីសង្វាក់គ្នានេះរួមមានផងដែរនូវ ភាពផ្ទុយគ្នានៃកាលបរិច្ឆេទ ទីតាំងផ្លាស់ទីលំនៅទៅប្រទេសកម្ពុជា មូលហេតុនៃការផ្លាស់ទី និងពេលវេលាដែលឪពុកម្តាយរបស់គាត់ ត្រូវបានគេសម្លាប់។<br><br>នៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះ (D5/82) អ្នកដាក់ពាក្យសុំអះអាងថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់រស់នៅភូមិគោល ក្នុងប្រទេសវៀតណាម ហើយនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៦ គាត់រួមជាមួយអ្នកដទៃទៀត ត្រូវបានគេដឹកបញ្ជូនមកកម្ពុជា។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ សមាជិកគ្រួសារគាត់ប្រាំបីនាក់ (រួមទាំងឪពុកម្តាយគាត់ផង) ត្រូវបានគេដឹកយកទៅតាមរថយន្ត ហើយក៏បាត់ខ្លួនទៅ។<br><br>ផ្ទុយទៅវិញ នៅក្នុងទម្រង់ព័ត៌មានបន្ថែម (D5/82.1) អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា នៅថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥ ឪពុកម្តាយរបស់គាត់ ត្រូវបានផ្លាស់ទីដោយបង្ខំ ពីទីក្រុងភ្នំពេញទៅភ្នំដិន នៅក្នុងខេត្តតាកែវ ហើយបន្ទាប់មកត្រូវបានខ្មែរក្រហមសម្លាប់ នៅប្រហែលកន្លះខែក្រោយមក។ ពេលវេលានិងសូម្បីតែទីតាំង នៃការសម្លាប់ឪពុកម្តាយរបស់គាត់ គឺមានភាពខុសគ្នា។ លើសពីនេះទៀត អ្នកដាក់ពាក្យសុំក៏បានរៀបរាប់ផងដែរ នៅពាក់កណ្តាលឆ្នាំ១៩៧៦ វៀតណាមបានផ្លាស់ទី | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| | | គាត់ ដោយសារតែគោលនយោបាយផ្លាស់ប្តូរ រវាងវៀតណាមនិងកម្ពុជា ហើយគាត់ត្រូវផ្លាស់ទីទៅភូមិព្រៃតាខាប (ខេត្តតាកែវ)។<br><br>នៅក្នុងសក្ខីកម្មក្នុងតុលាការ របស់អ្នកដាក់ពាក្យសុំ គាត់បានរៀបរាប់ថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់ត្រូវបានផ្លាស់ទីពីកម្ពុជាក្រោម ទៅព្រៃខាប (ខេត្តតាកែវ) ហើយម្តាយរបស់គាត់បានសុំឱ្យគាត់ ផ្លាស់ទីទៅព្រៃខាបខ្មែរលើ (upper Cambodia Prey Khab) ដោយសារតែទីនោះសំបូរអាហារ។ ចំណុចនេះគឺផ្ទុយជាមួយមូលហេតុ គោលនយោបាយផ្លាស់ប្តូរ ដែលគាត់បានរៀបរាប់កន្លងមក។ | |
| 13-VSS-00512 | ស៊ិន អ៊ីម | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឡើយក្នុងការសម្រេចថា ភាពមិនស៊ីសង្វាក់គ្នានៃកាលបរិច្ឆេទកំណត់របស់ អ្នកដាក់ពាក្យសុំ ធ្វើឱ្យពាក្យសុំតាំងខ្លួន មិនអាចទទួលយកបាន។ បើទោះបីជាមិនមានបញ្ហាលើអត្តសញ្ញាណក្តី តែហេតុការណ៍ដែលបានចោទឡើង ស្ថិតក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។<br><br>អត្តសញ្ញាណប័ណ្ណរបស់អ្នកដាក់ពាក្យសុំ បង្ហាញពីឆ្នាំកំណត់គឺ ១៩៧៣ ដែលប្រឆាំងនឹងព័ត៌មានរបស់គាត់ អំពីការសម្លាប់ឪពុកម្តាយក្មេកគាត់ នៅក្នុងឆ្នាំ១៩៧៨ ដែលក្នុងពេលនោះអ្នកដាក់ពាក្យសុំ មានអាយុត្រឹមប្រាំឆ្នាំ។<br><br>អ្នកដាក់ពាក្យសុំបានរៀបរាប់អំពីហេតុការណ៍ ដែលរួមមានផងដែរនូវការជម្លៀសដោយបង្ខំ ពីស្រុកស្វាយអន្ទរ (ខេត្តព្រៃវែង) ទៅស្រុកបាកាន (ខេត្តពោធិ៍សាត់) និងការសម្លាប់ក្រុមគ្រួសារនៅ | ពាក្យសុំតាំងខ្លួន**មិនអាចទទួលយកបាន**។ សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបាន**តម្កល់**។ |

| | | | |
|---|---|---|---|
| | | ភូមិវាល ឃុំតាល្វ ស្រុកបាកាន (ខេត្តពោធិ៍សាត់) គឺជាទីតាំងដែលស្ថិតនៅក្រៅវិសាលភាពទីតាំងនៃសំណុំរឿង។ | |
| 12-VSS-00672 | ញឹម កុល | សេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការប្រកាសថា ពាក្យសុំតាំងខ្លួនរបស់ ញឹម កុល មិនអាចទទួលយកបាន ដោយផ្អែកលើមូលដ្ឋានថា គាត់គឺជាកម្មាភិបាលខ្មែរក្រហម គឺមានកំហុសឆ្គង។ កន្លងមកនៅក្នុងសំណុំរឿង ០០២ អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួន ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដូចជាដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន (D22/2479) និងដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-235 ដែលពួកគាត់ទាំងពីរជា អតីតកម្មាភិបាលខ្មែរក្រហម។<br><br>ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងវិសាលភាព ទីតាំងនិងពេលវេលានៃសំណុំរឿង ញឹម កុល បានរៀបរាប់ពីការចាប់ខ្លួន និងការសម្លាប់ជាច្រើន ទៅលើសាច់ញាតិគ្រួសារគាត់ ដូចជាការសម្លាប់ពូរបស់គាត់ (ញឹម ឌៃ អតីតទាហានលន់ នល់) និងក្រុមគ្រួសារគាត់នៅភ្នំប្រុសភ្នំស្រី ក្នុងឆ្នាំ១៩៧៧ (ឯកសារ D5/676 នៅត្រង់ ERN 00911604) ការធ្វើទារុណកម្ម និងសម្លាប់នៅពេលក្រោយមកលើពូរបស់គាត់ (ឈ្មោះ ឈួន ស៊ីម) នៅវត្តអង្គញជី ប្រហែលក្នុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨ (ឯកសារ D219/171 ឆ. ២៥) និងការចាប់ខ្លួនពូរបស់គាត់ (ផាន់ ស៊ីម ជាអតីតមេឃុំ និងជាសមាជិកគណៈកម្មាធិការស្រុកព្រៃឈរ) នៅមន្ទីរសន្តិសុខតំបន់ នៅវត្តតាមាឃ ជាផ្នែកមួយនៃការបោស | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គង។ ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី (D5/676) គួរត្រូវបាន**ទទួលយក**។ |

| | | | |
|---|---|---|---|
| | | សម្អាត កម្មាភិបាលដែលកំពុងកាន់តំណែង ក្រោយពេលក្រុមភូមិភាគនិរតីមកដល់ ភូមិភាគកណ្តាល(ឯកសារ D219/171 ឆ.១១, ឆ.១៦)។<br><br>ចាប់ពីខែមិថុនា ឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៨ ញឹម កុល ទទួលខុសត្រូវកងពាណិជ្ជកម្ម ឃុំក្រឡារ ហើយគាត់កាន់ខាងបែងចែកអង្ករ និងអំបិល នៅថ្នាក់ឃុំ, ទទួលខាងកត់ត្រាកិច្ចប្រជុំថ្នាក់ឃុំនិងស្រុក, រក្សាកំណត់ត្រានិងស្ថិតិប្រជាជន និងផលិតផល និងជ្រើសរើសមនុស្សទៅធ្វើការនៅតាមចំការ នៅក្នុងស្រុកចំការលើ តំបន់៤២។ អង្គហេតុដែលថាអ្នកដាក់ពាក្យសុំ បានឃើញការធ្វើទារុណកម្ម ពូគាត់ម្នាក់ (ឈ្មោះ ឈួន ស៊ីម) នៅពេលដែលគាត់នៅជាកម្មាភិបាលខ្មែរក្រហមនោះ មិនរារាំងគាត់ក្នុងការទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ទោះបីជា ញឹម កុល "ឈរនៅទីនោះ" ពេលសួរចម្លើយពូគាត់ក្តី តែមេបញ្ជាការខ្មែរក្រហម (ផុន) ធ្វើការសួរចម្លើយ ហើយមិនមានការបញ្ជាក់ថា ញឹម កុល បានចូលរួម ឬប្រព្រឹត្តការធ្វើទារុណកម្មឡើយ។ តាមពិតទៅភស្តុតាងបង្ហាញថា ញឹម កុល មិនមានសិទ្ធិអំណាច បញ្ឈប់ការធ្វើទារុណកម្មឡើយ (ឯកសារ D219/171 ឆ.២៦៖ "ខ្ញុំនៅតែមានអារម្មណ៍ក្តុកក្តួល ពេលដែលខ្ញុំនឹកឃើញពាក្យរបស់ ស៊ីម ប្រាប់ថា ឲ្យខ្ញុំជួយមើល កូនចៅរបស់គាត់ផង" ស. តើការសួរចម្លើយនេះ គឺជាគំនិតផុសចេញពីផុត ឬមួយក៏ ប្រាក់ យុត បានដឹងដែរអំពីរឿងនេះ? ឆ.២៩ ខ្ញុំគិតថា គេធ្វើនេះគឺទៅតាមចិត្តរបស់គេរៀងៗខ្លួន...")។ តាមពិតទៅ ញឹម កុល ត្រូវបានគេប្រាប់នៅពេលក្រោយមកថា ពូរបស់ | |

| | | | |
|---|---|---|---|
| | | គាត់ "ត្រូវគេយកទៅសម្លាប់" ដែលនេះបង្ហាញថា គាត់មិនមានវត្តមានឡើយ នៅពេលសម្លាប់នោះ។<br><br>សំខាន់បំផុតនោះ ទោះជាក្នុងករណីណាក៏ដោយ មិនមានភ័ស្តុតាងបង្ហាញថា ញ៉ឹម កុល គឺជាថារី ឬបានចូលរួមចំណែក ក្នុងការចាប់ខ្លួន និងការស្លាប់ សាច់ញាតិគ្រួសារគាត់ដទៃទៀត រួមទាំងពួពីរនាក់ (ដែលបានរៀបរាប់ខាងលើ) ហើយសហាចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏មិនបានសម្រេចបែបនេះ នៅក្នុងសំអាងហេតុរបស់គាត់ដែរ។ | |